# សេចក្តីថ្លែងការណ៍
## ក្នុងឱកាសទិវាអ្នកប្តូរភេទអន្តរជាតិដោយបើកចំហ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
## សូមអំពាវនាវឲ្យរដ្ឋាភិបាលលើកកម្ពស់ និងការពារសិទ្ធិមនុស្ស
## របស់អ្នកប្តូរភេទនៅក្នុងប្រទេសកម្ពុជា

**រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥**

ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ គឺជាទិវាខួបទីប្រាំមួយនៃអ្នកប្តូរភេទអន្តរជាតិដោយបើកចំហ។ នៅថ្ងៃនេះមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(“ម.ស.ម.ក”) សូមអំពាវនាវឲ្យរាជរដ្ឋាភិបាលកម្ពុជា បោះជំហានទៅមុខជាវិជ្ជមាន ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្សរបស់អ្នកប្តូរភេទនៅប្រទេសកម្ពុជា។

មុនពេលដែលទិវាអ្នកប្តូរភេទអន្តរជាតិដោយបើកចំហជាលើកដំបូង ត្រូវបានសកម្មជននៅសហរដ្ឋអាមេរិករៀបចំឡើងនៅឆ្នាំ២០០៩ ទិវាអន្តរជាតិមួយផ្សេងទៀតដែលបានប្រារព្ធឡើងដើម្បីឧទ្ទិសដល់សហគមន៍អ្នកប្តូរភេទពោលគឺទិវាចងចាំនៃក្រុមអ្នកប្តូរភេទ គឺជាថ្ងៃកាន់ទុក្ខចំពោះមនុស្សដែលត្រូវបានសម្លាប់ ដោយសារការរើសអើងទាក់ទងនឹងការបង្ហាញអត្តសញ្ញាណយេនឌ័រ។ ដូច្នេះ ថ្ងៃទី៣១ ខែមីនា គឺជាថ្ងៃដែលត្រូវបានប្រារព្ធឡើង ដើម្បីអបអរសហគមន៍អ្នកប្តូរភេទនៅជុំវិញពិភពលោក។

នៅប្រទេសកម្ពុជាបញ្ហារបស់អ្នកប្តូរភេទមិនទាន់ស្រាវជ្រាវយ៉ាងទូលំទូលាយនៅឡើយនោះទេ ហើយក៏មិនមានទិន្នន័យច្បាស់លាស់ ទាក់ទងនឹងការរើសអើងប្រឆាំងនឹងក្រុមអ្នកប្តូរភេទនោះដែរ។ ទោះបីជាយ៉ាងណាក៏ដោយ គម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ(គម្រោងសូជី)របស់(“ម.ស.ម.ក”) បានទាក់ទងជាមួយបណ្តាញដ៏ធំមួយនៃក្រុមអ្នកប្តូរភេទនៅទូទាំងប្រទេស ដោយអ្នកមួយចំនួនស្នើឡើងថា ការរើសអើងទៅលើអ្នកប្តូរភេទ គឺមិនមែនជារឿងចម្លែកនោះទេ មិនថានៅកន្លែងធ្វើការ និងនៅសាលារៀន។

ការរើសអើងប្រឆាំងនឹងក្រុមមនុស្សដែលប្តូរភេទ គឺជាបញ្ហាមួយដែលត្រូវបានគេសិក្សាលម្អិតនៅកន្លែងដទៃទៀតផងដែរ នៅក្នុងពិភពលោក ហើយលទ្ធផលនៃការរកឃើញនោះពិតជាគួរឲ្យព្រួយបារម្ភ។ ក្នុងនោះដែរ នៅចន្លោះឆ្នាំ២០០៨-២០១៤ គម្រោងឃ្លាំមើលឃាតកម្មទៅលើអ្នកប្តូរភេទរបស់អឺរ៉ុប បានរកឃើញករណីឃាតកម្មលើក្រុមអ្នកប្តូរភេទសរុបចំនួន ១.៥០៩ ករណីនៅទូទាំងពិភពលោក។ នៅក្នុងចក្រភពអង់គ្លេស ការសិក្សាមួយនៅឆ្នាំ ២០១៤ ក៏បានរកឃើញដែរថា ៤៨% នៃអ្នកប្តូរភេទអាយុក្រោម ២៦ ឆ្នាំ បានព្យាយាមធ្វើអត្តឃាត បើប្រៀបធៀបទៅនឹងអ្នកដែលមិនមែនជាអ្នកប្តូរភេទស្របាលគ្នាមានតែ ២៦,២៥%។

នៅខែកុម្ភៈ ឆ្នាំ២០១៤ អ្នកស្រី**ស៊ូ សុធារី** ជាសកម្មជនអ្នកប្តូរភេទកម្ពុជា និងជានាយិកាប្រតិបត្តិនៃបណ្តាញប្រជាជនកម្ពុជាសម្រាប់អភិវឌ្ឍបុរសស្ត្រី បានទទួលពានរង្វាន់អន្តរជាតិដែលមានឈ្មោះថាឌេវីតកាតូវីស្សុនអេនវ៉ស្ស(David Kato Vision and Voice Award)។ លោកឌេវីតកាតូ(David Kato) ជាសកម្មជន

លេចធ្លោរបស់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសអ៊ូហ្គង់ដាដែលត្រូវបានគេធ្វើឃាតនៅឆ្នាំ២០១១។ ពានរង្វាន់ដ៏ខ្ពង់ខ្ពស់នេះគឺជាការទទួលស្គាល់ និងគាំទ្រការងាររបស់មេដឹកនាំទាំងឡាយ ដូចជាលោកឌេវីតកាតូ (David Kato) ដែលបានតស៊ូស្វិតស្វាញលើកកម្ពស់សិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់អ្នកស្រឡាញ់ភេទដូចគ្នានៅជុំវិញពិភពលោក។

**និយាយអំពីសហគមន៍អ្នកប្តូរភេទនៅកម្ពុជា និងភាពចាំបាច់ក្នុងការចេញមុខជាសាធារណៈ សកម្មជនដែលជាម្ចាស់ពានរង្វាន់ លោកស្រី ស៊ូ សុធារី មានប្រសាសន៍ថា ៖**

*"ក្នុងនាមជាអ្នកប្តូរភេទ ការចេញមុខដោយបើកចំហ តែងជួបបញ្ហាជាញឹកញាប់។ ការជជែកពិភាក្សាដោយបើកចំហ និងអារម្មណ៍ថាមានសុវត្ថិភាពគ្រប់គ្រាន់ ក្នុងការចេញមុខនៅក្នុងក្រុមគ្រួសារ និងមិត្តភក្តិ គឺជាកត្តាដ៏សំខាន់ក្នុងការបង្កើនការយល់ដឹងអំពីបញ្ហាអ្នកប្តូរភេទក្នុងចំណោមសាធារណៈជនទូទៅ ។ មានតែសាធារណៈជនយល់ដឹងពីបញ្ហាសហគមន៍អ្នកប្តូរភេទនោះទេទើបពួកគាត់ទទួលស្គាល់សហគមន៍អ្នកប្តូរភេទ"។*

ទិវាអន្តរជាតិនៃអ្នកប្តូរភេទចេញជាចំហ គឺមិនត្រឹមតែជាថ្ងៃទទួលស្គាល់នៃការរួមចំណែករបស់បុគ្គលអ្នកស្រី ស៊ូ សុធារី ម្នាក់ប៉ុណ្ណោះ ថែមទៀតក៏ជាការទទួលស្គាល់ពីតួនាទីរបស់អ្នកប្តូរភេទទាំងអស់នៅក្នុងសង្គម និង អបអរសាទរពីភាពចម្រុះបែបនៅកម្ពុជាផងដែរ។

**លោក នួន ស៊ីដារ៉ា អ្នកសម្របសម្រួលគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនៃ ម.ស.ម.ក មានប្រសាសន៍ថា ៖**

*"ជាអកុសលមនុស្សដែលជាអ្នកប្តូរភេទនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាសមាជិកដទៃទៀតដែលជាសហគមន៍ស្រីស្រឡាញ់ ស្រីប្រុសស្រឡាញ់ប្រុស និងអ្នកស្រឡាញ់បានទាំងពីរភេទតែងតែជួបនឹងការប្រឈមនឹងការមិនអត់ឱន និងការរើសអើងពីសំណាក់ក្រុមគ្រួសារ និងសង្គមយ៉ាងខ្លាំង។ យើងចង់ឃើញការផ្លាស់ប្តូរឥរិយាបទមួយដែលជួយឲ្យអ្នកប្តូរភេទមានអារម្មណ៍ថាខ្លួនត្រូវបានគេទទួលស្គាល់ និងមានសុវត្ថិភាពនៅក្នុងសហគមន៍របស់ខ្លួន។ រដ្ឋាភិបាលគួរតែធ្វើជាគំរូ និងលើកកម្ពស់ការពារសិទ្ធិរបស់បុរស និងស្ត្រីដែលបានប្តូរភេទដើម្បីអោយមានការរស់នៅដោយមិនមានការរើសអើង"។*

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក នួន ស៊ីដារ៉ា អ្នកសម្របសម្រួលគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនៃ ម.ស.ម.ក តាមរយៈទូរសព្ទ ៖ +៨៥៥ (០) ៩៧ ៩៦៦៦ ៥៦៦ ឬអ៊ីម៉ែល ៖** sidara.nuon@cchrcambodia.org **ឬលោក ធីម ម៉ូលីញ៉ូវ តាមរយៈទូរសព្ទ៖ +៨៥៥ (០) ៩៦ ៩៣៩ ៥២៩៦ ឬអ៊ីម៉ែល ៖** tim.molyneux @cchrcambodia.org។

**បណ្ណាធិការ ៖**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ដែលបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក ជាសមាជិកអង្គការពិភពលោកប្រឆាំងនឹងការធ្វើទារុណកម្ម ("OMCT") បណ្តាញទារុណកម្ម អេស អូ អេស, សមាជិកនៃដៃគូរសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អាយហ្វិច) ដែលបណ្តាញសាកល សម្រាប់សេរីភាពក្នុងការបញ្ចេញមតិ និងសម្ព័ន្ធអ្នកសារព័ត៌មានអាស៊ីអាគ្នេយ៍("SEAPA") និងជាសមាជិកនៃ សម្ព័ន្ធពិភពលោកដើម្បីការចូលរួមរបស់ប្រជាពលរដ្ឋ ("CIVICUS")ផងដែរ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើត សង្គមព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព" និងជ័យលាភីបានទទួលពានរង្វាន់ផ្នែក ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គមប្រចាំឆ្នាំ២០១៣ ដែលផ្តល់ជូនដោយមជ្ឈមណ្ឌលទំនាក់ទំនង និងការ ផ្លាស់ប្តូរសង្គមនៃសាកលវិទ្យាល័យឃ្វីនឡែន ក្នុងរដ្ឋប្រីសបែន ប្រទេសអូស្ត្រាលី។